ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាធម្មនុញ្ញ

# សារលិខិតរំលែកទុក្ខ

## ជូនចំពោះ
## លោកជំទាវ កែប ស៊ុំ និងក្រុមគ្រួសារ

ក្នុងនាមក្រុមប្រឹក្សាធម្មនុញ្ញ ខ្ញុំនិងភរិយា ព្រមទាំងមន្ត្រីរាជការនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ មានសេចក្តីក្រៀមក្រំក្រៃលែង និងសោកស្តាយជាអនេក ចំពោះដំណឹងអំពីមរណភាពរបស់ឯកឧត្តម **អ៊ុំ ម៉ាន្ធូរីន** សមាជិកព្រឹទ្ធសភា នៅថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧ វេលាម៉ោង ៨:៤៥ នាទីព្រឹក ក្នុងជន្មាយុ ៩៣ឆ្នាំ ដោយជរាពាធ។

យើងខ្ញុំ សូមចូលរួមរំលែកមរណទុក្ខជាមួយនឹងលោកជំទាវ **កែប ស៊ុំ** និងក្រុមគ្រួសារ ចំពោះការបាត់បង់ឧត្តមស្វាមី ឪពុក ឪពុកក្មេក និងជីតា ជាទីគោរពស្រឡាញ់ និងប្រកបដោយព្រហ្មវិហារធម៌ ហើយក៏ជាការបាត់បង់នូវបញ្ញវន្តដ៏ឆ្នើម និងជាឥស្សរជនខ្មែរមួយរូប ដែលបានលះបង់កម្លាំងកាយ ប្រាជ្ញាស្មារតី ដើម្បីបុព្វហេតុជាតិមាតុភូមិ និងប្រជាពលរដ្ឋ ព្រមទាំងបានចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍស្ថាប័នព្រឹទ្ធសភា ការពារអធិបតេយ្យជាតិ បូរណភាពទឹកដី រួមចំណែកពង្រឹងនីតិរដ្ឋ លទ្ធិប្រជាធិបតេយ្យ និងលើកកម្ពស់កិត្យានុភាពជាតិទាំងក្នុងតំបន់ និងលើពិភពលោក។

យើងខ្ញុំ សូមលំឱនកាយលើកហត្ថបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជៈបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ តាមជួយបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធឯកឧត្តម **អ៊ុំ ម៉ាន្ធូរីន** បានទៅសោយសុខក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូមលោកជំទាវ និងក្រុមគ្រួសារ មេត្តាទទួលនូវការចូលរួមរំលែកមរណទុក្ខដ៏សែនក្រៀមក្រំបំផុតនេះ ដោយស្មោះអស់ពីដួងចិត្តនៃយើងខ្ញុំទាំងអស់គ្នា។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៧

**ប្រធានក្រុមប្រឹក្សាធម្មនុញ្ញ**

**អ៊ឹម ឈុនលឹម**

អាគារស វិមានរដ្ឋចំការមន មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ
ទូរស័ព្ទ/ ទូរសារ : (៨៥៥) ២៣ ៧២០ ៩១៣. E-mail: sgcc@camnet.com.kh/ info@ccc.gov.kh, Website :http://www.ccc.gov.kh